# សន្ទរកថា
# ឯកឧត្តមបណ្ឌិត អូន ព័ន្ធមុនីរ័ត្ន
# រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
# ថ្លែងក្នុងកម្មវិធីសម្ពោធដាក់ឱ្យប្រើប្រាស់គេហទំព័រនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម
# (National Trade Repository-NTR)
# នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
# ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៥

- ***ឯកឧត្តម Alassane SOW អ្នកគ្រប់គ្រងប្រចាំកម្ពុជា នៃធនាគារពិភពលោក***
- ***ឯកឧត្តម Christopher George Edga ឯកអគ្គរាជទូតសហភាពអឺរ៉ុបប្រចាំប្រទេសកម្ពុជា***
- ***ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ !***

ថ្ងៃនេះ, ខ្ញុំមានសេចក្តីសោមនស្សរីករាយដែលបានចូលរួមបើកកម្មវិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៃ ***"គេហទំព័រនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម - National Trade Repository-NTR"*** ។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះសហភាពអឺរ៉ុប (EU) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិដាណឺម៉ាក (DANIDA) អង្គការអភិវឌ្ឍន៍ឧស្សាហកម្មរបស់អង្គការសហប្រជាជាតិ (UNIDO) និងធនាគារពិភពលោក (World Bank) ដែលបានផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីបង្កើតគេហទំព័រនៃនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មនេះក្នុងគោលបំណងជួយសម្រួលការធ្វើពាណិជ្ជកម្មនៅប្រទេសកម្ពុជា ។

ដូចយើងបានដឹងហើយថា កម្ពុជាបាន និងកំពុងត្រៀមខ្លួនចូលរួមធ្វើសមាហរណ-កម្មក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន នាចុងឆ្នាំ ២០១៥ នេះ ដែលក្នុងនោះយើងនឹងឃើញនូវលំហូរដោយសេរីនៃទំនិញ, សេវា, ពលករជំនាញ និង ការវិនិយោគ ក្នុងតំបន់អាស៊ាន ។ ចំពោះលំហូរដោយសេរីនៃទំនិញ, អាស៊ានបានជំរុញយ៉ាងខ្លាំងក្លាលើការធ្វើសេរីភាវូបនីយកម្មពន្ធគយ ចាប់តាំងពីមានការបង្កើតនូវផែនការមេសហគមន៍សេដ្ឋកិច្ចអាស៊ាន (ASEAN Economic Community Blueprint) ពីឆ្នាំ ២០០៧ មក ។ លើសពីនេះទៅទៀត, កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន (ASEAN Trade In Goods Agreement - ATIGA) គឺជាយន្តការដ៏សំខាន់មួយសម្រាប់ជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មតាមរយៈការធ្វើឱ្យមានភាពសាមញ្ញនៃដំណើរការ និងនីតិវិធី ដែលអាចកាត់បន្ថយពេលវេលាក្នុងការធ្វើធុរកិច្ច ហើយក៏ជួយសម្រួលដល់សាធារណជនទូទៅផងដែរ ។

ដើម្បីឆ្លើយតបទៅនឹងមាត្រា ១៣ ជំពូកទី ១ ដែលមានចែងក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន (ATIGA), កម្ពុជា, ក្នុងនាមជាសមាជិកហត្ថលេខី និងអ្នក-ទទួលផល, មានកាតព្វកិច្ចក្នុងការធានាឱ្យព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មអាចជ្រាបដល់សាធារណៈជនតាមរយៈប្រព័ន្ធអ៊ីនធឺណេត ។ ក្នុងបរិការណ៍នេះ និហិតដ្ឋានព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្មអាស៊ាន នឹងក្លាយជាកត្តាជំរុញដ៏សំខាន់ដើម្បីជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងក្នុងតំបន់ទាំងមូល ដោយសារថា គេហទំព័រនេះ អនុញ្ញាតឱ្យពាណិជ្ជករចូលទៅទាញយកបាននូវព័ត៌មានពាណិជ្ជកម្មសំខាន់ៗដូចជា **(i)តារាងនាមវលី; (ii)តារាងពន្ធប្រជាជាតិអនុគ្រោះបំផុត និងតារាងពន្ធអនុគ្រោះក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញអាស៊ាន និងដៃគូ; (iii)វិធានដើមកំណើតទំនិញ; (iv)វិធានការមិនមែនពន្ធ; (v)ច្បាប់និងលិខិតបទដ្ឋានគតិយុត្តិពាណិជ្ជកម្ម និងច្បាប់និងលិខិតបទដ្ឋានគតិយុត្តគយ; (vi)នីតិវិធីនិងឯកសារតម្រូវផ្សេងៗ; (vii)សេចក្តីសម្រេចរដ្ឋបាល; (viii)ឧត្តមានុវត្តក្នុងការសម្រួលពាណិជ្ជកម្ម;**

**(ix) បញ្ជីពាណិជ្ជករដែលបានទទួលការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការពាណិជ្ជ-កម្ម និងព័ត៌មានពាណិជ្ជកម្មផ្សេងៗទៀត ។**

ធាតុផ្សំទាំងនេះ គឺជាឧបករណ៍ចាំបាច់សម្រាប់ពន្លឿនប្រតិបត្តិការពាណិជ្ជកម្ម ដែលអាចធ្វើឱ្យប្រសើរឡើង នូវវដ្តពាណិជ្ជកម្មទាំងមូលនៅក្នុងប្រទេស ។ កត្តានេះនឹងរួមចំណែកដល់កំណើនសេដ្ឋកិច្ច និងជំរុញការកើនឡើងនៃសហគ្រាសធុនតូច និងមធ្យម ដែលស្របជាមួយនឹង ***យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី III ដើម្បីកំណើន ការងារ សមភាព និងប្រសិទ្ធិភាព*** នៃរាជរដ្ឋាភិបាលកម្ពុជា ។

ខ្ញុំជឿជាក់យ៉ាងមុតមាំថា គំនិតផ្តួចផ្តើមនេះ អាចឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្ត របស់កម្ពុជា ក្នុងនាមជាសមាជិកអាស៊ាន ក្នុងការកែលម្អស្តង់ដារពាណិជ្ជកម្មមួយដែលមានលក្ខណៈងាយស្រួល និងអំណោយផលដល់ពាណិជ្ជករក្នុង និងក្រៅប្រទេស ហើយក៏ឆ្លើយតបទៅនឹងការអនុវត្តនូវកាតព្វកិច្ចរបស់ប្រទេសកម្ពុជាក្នុងនាមជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោកផងដែរ។

***ឯកឧត្តម លោកជំទាវ លោក លោកស្រី !***

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសំដែងនូវការកោត-សរសើរជាថ្មីម្តងទៀត ជូនចំពោះដៃគូរអភិវឌ្ឍន៍ទាំងអស់ដែលបានផ្តល់ជំនួយបច្ចេកទេស និងការកសាងសមត្ថភាពដល់មន្ត្រីនៃលេខាធិការដ្ឋាន NTR និង NTM ។ ខ្ញុំក៏សូមកោតសរសើរនាយកដ្ឋានសមាហរណកម្មសេដ្ឋកិច្ច និងអាស៊ាន នៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្នុងតួនាទីជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការ NTR និង NTM, ដែលបានខិតខំប្រឹងប្រែងប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ ក្នុងការសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត ដើម្បីបង្កើតបាននូវគេហទំព័រ NTR ដ៏មានសារៈប្រយោជន៍នេះ ។

មុននឹងបញ្ចប់ ខ្ញុំសូមស្នើឱ្យលេខាធិការដ្ឋានបន្តកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីបន្តធ្វើបច្ចុប្បន្នភាពគេហទំព័រដ៏ចាំបាច់មួយនេះ ឱ្យមានអន្តរសកម្មជាមួយ និង លក្ខណៈងាយស្រួលសម្រាប់អ្នកប្រើប្រាស់ ក្នុងគោលបំណងបង្កើនចំនួនអ្នកចូលទស្សនាគេហទំព័រនេះ ។ ខ្ញុំក៏សូមលើកទឹកចិត្តឱ្យតួអង្គពាក់ព័ន្ធទាំងអស់ ទាំងនៅក្នុងស្ថាប័នរដ្ឋ និង ឯកជន មេត្តាប្រើប្រាស់បណ្តាញវេទិកានេះឲ្យបានច្រើន ដើម្បីទាញយកផលប្រយោជន៍តាមតម្រូវការរៀងៗខ្លួន ។

*ខ្ញុំសូមប្រកាស**បើកឱ្យប្រើប្រាស់ជាផ្លូវការនៃគេហទំព័រនិហិតដ្ឋានជាតិព័ត៌មានពាក់ព័ន្ធនឹងពាណិជ្ជកម្ម** ចាប់ពីពេលនេះតទៅ ។*

ខ្ញុំសូមជូនពរឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ សូមប្រកបនូវពុទ្ធពរទាំងបួនប្រការគឺ ***អាយុ វណ្ណៈ សុខ ពលៈ*** កុំបីឃ្លៀងឃ្លាតឡើយ ។